# ព្រះរាជក្រម

នស/រកម/១២២៣/ ០៥៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល លេខ:...៣៥២
ថ្ងៃទី១២..ខែ.ធ្នូ...ឆ្នាំ២០២៣
ម៉ោង:..១១:០៥..

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការទូទាត់ថវិកាទូទៅរបស់រដ្ឋ
# សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **ក១** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៣០ ៥៤៤ ៣៦៦,០ លានរៀល
- អនុវត្តជាក់ស្តែង........................................៣២ ២៩៩ ៣៣០,៩ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុ........................................ ១ ៧៥៤ ៩៦៤,៩ លានរៀល។

**មាត្រា៣ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៣៣ ០៧៩ ២៦៦,០ លានរៀល
- អនុវត្តជាក់ស្តែង........................................២៩ ៨៥០ ៤៤៧,២ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ........................................ ៣ ២២៨ ៨១៨,៨ លានរៀល។

**មាត្រា៤ .-**

ចំណូលថវិកាដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងចំណុច I នៃតារាង **ខ១** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ចំណាយថវិកាថ្នាក់ជាតិដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកនៅក្នុងតារាង **ឧ១** និងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានបង្ហាញលម្អិតតាមក្រសួងនិងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមប្រភេទនៅក្នុងតារាង **ឌ២** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

លទ្ធផលដែលសម្រេចបានពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តមិនឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ៖ ចំពោះចំណូលថវិកាត្រូវបានបង្ហាញនៅក្នុងចំណុច II នៃតារាង **១១** និងចំពោះចំណាយថវិកាត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **៣៣** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ផ្នែកទី២

## កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តឆ្លងកាត់រតនាគារជាតិ

**មាត្រា៥ .-**

ការប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................ ២៤ ៧៣០ ៨៨២,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២៦ ៦៩៤ ៧៩៦,៥ លានរៀល

ដូច្នេះ ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ........................................ ១ ៩៦៣ ៩១៤,៥ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ២២ ១៥៧ ៣៤៣,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២៤ ៨៦០ ៨៦៥,៨ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ................................ ២ ៧០៣ ៥២២,៨ លានរៀល។

២. ចំណូលមូលធន

- ច្បាប់ហិរញ្ញវត្ថុ........................................ ២ ៥៧៣ ៥៣៩,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ១ ៨៣៣ ៩៣០,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ................................ ៧៣៩ ៦០៨,៤ លានរៀល។

ក. ចំណូលមូលធនក្នុងប្រទេស

- ច្បាប់ហិរញ្ញវត្ថុ........................................ ១ ៣០៥ ២៥៩,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ១១៦ ០៣១,៧ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ................................ ១ ១៨៩ ២២៧,៣ លានរៀល។

ខ. ចំណូលមូលធនក្រៅប្រទេស(មូលនិធិទ្រទ្រង់ថវិកា)

- ច្បាប់ហិរញ្ញវត្ថុ........................................ ១ ២៦៨ ២៨០,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ១ ៧១៧ ៨៩៨,៩ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ................................ ៤៤៩ ៦១៨,៩ លានរៀល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៦ .-**

ការអនុវត្តចំណាយថវិកាថ្នាក់ជាតិអនុវត្តឆ្លងកាត់រតនាគារជាតិ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.................................... ២៧ ២៦៥ ៧៨២,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ២៤ ២៤៥ ៩១២,៨ លានរៀល

ដូច្នេះ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ.................................... ៣ ០១៩ ៨៦៩,២ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត
- ច្បាប់ហិរញ្ញវត្ថុ.................................... ១៩ ១១១ ៧០៤,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ១៧ ៨៨៨ ៣១២,៦ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................... ១ ២២៣ ៣៩១,៤ លានរៀល។

២. ចំណាយមូលធន
- ច្បាប់ហិរញ្ញវត្ថុ.................................... ៨ ១៥៤ ០៧៨,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៦ ៣៥៧ ៦០០,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................... ១ ៧៩៦ ៤៧៧,៨ លានរៀល។

ក. ចំណាយមូលធន សម្រាប់វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
- ច្បាប់ហិរញ្ញវត្ថុ.................................... ៦ ៦៧៦ ៤២១,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៤ ៩០៥ ៦៥៤,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................... ១ ៧៧០ ៧៦៦,៩ លានរៀល។

ខ. ចំណាយមូលធន សម្រាប់ការទូទាត់ការខ្ចី
- ច្បាប់ហិរញ្ញវត្ថុ.................................... ១ ៤៧៧ ៦៥៧,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ១ ៤៥១ ៩៤៦,១ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................... ២៥ ៧១០,៩ លានរៀល។

**មាត្រា៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាជាក់ស្តែងឆ្លងកាត់រតនាគារជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.................................... ២៦ ៦៩៤ ៧៩៦,៥ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.................................... ២៤ ២៤៥ ៩១២,៨ លានរៀល
- អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ.................................... (+)២ ៤៤៨ ៨៨៣,៧ លានរៀល។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៧៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ មានចំនួនទឹកប្រាក់(+)២ ៤៤៨ ៨៨៣,៧ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផលរបស់រតនាគារជាតិ។

# ផ្នែកទី៣
# បទប្បញ្ញត្តិស្តីពី
# និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែម

**មាត្រា៨ .-**

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងយោងមាត្រា១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងយោងតាមតម្រូវការចាំបាច់ជាក់ស្តែងរបស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុម័តយល់ព្រមលើកិច្ចប្រតិបត្តិការចំណាយឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅៈ

ក. ផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ឥណទានថវិកាបន្ថែម.............................................៥០២ ៤០០,០ លានរៀល
- អនុវត្តជាក់ស្តែង..................................................៤៩៣ ៥៨៩,៨ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.................................៨ ៨១០,២ លានរៀល

សម្រាប់ចំណាយដូចខាងក្រោមៈ

ក.១. ចំណាយលើការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជួយគ្រួសារក្រីក្រនិងងាយរងគ្រោះ

- ឥណទានថវិកាបន្ថែម.............................................៣៧៩ ៤០០,០ លានរៀល
- អនុវត្តជាក់ស្តែង..................................................៣៧៩ ៤០០,០ លានរៀល។

ក.២. ចំណាយលើការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ(គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ដែលងាយរងផលប៉ះទង្គិចពីសម្ពាធអតិផរណា

- ឥណទានថវិកាបន្ថែម.............................................១២៣ ០០០,០ លានរៀល
- អនុវត្តជាក់ស្តែង..................................................១១៤ ១៨៩,៨ លានរៀល
- ទាបជាងឥណទានថវិកាបន្ថែម.................................៨ ៨១០,២ លានរៀល។

ខ. ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់

- ឥណទានថវិកាបន្ថែម.............................................២៣៨ ៧៩៥,៤ លានរៀល
- អនុវត្តជាក់ស្តែង..................................................២៣៨ ៧៩៥,៤ លានរៀល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ផ្នែកទី៤

# កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាអនុវត្តមិនឆ្លងកាត់រតនាគារជាតិ

**មាត្រា៩ .-**

ការអនុវត្តចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តមិនឆ្លងកាត់រតនាគារជាតិ ដែលបានគ្រោងទុកចំណូលសរុបស្មើនឹងចំណាយសរុបសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៥ ៨១៣ ៤៨៤,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................... ៥ ៦០៤ ៥៣៤,៤ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ២០៨ ៩៤៩,៦ លានរៀល។

# ផ្នែកទី៥

# តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

**មាត្រា១០ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលក្នុងប្រទេសអនុវត្តជាក់ស្តែង.................២៤ ៩០៤ ៧៩៧,៥ លានរៀល
  + ចំណូលចរន្តអនុវត្តជាក់ស្តែង..................... ២៤ ៨៦០ ៨៦៥,៨ លានរៀល
  + ចំណូលមូលធនក្នុងប្រទេសអនុវត្តជាក់ស្តែង (មិនគិតបញ្ចូលចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ)................................ ៤៣ ៩៣១,៧ លានរៀល
- ចំណាយថវិកាសរុបអនុវត្តជាក់ស្តែង.................២៨ ៣៩៨ ៥០១,១ លានរៀល
  + ចំណាយចរន្តអនុវត្តជាក់ស្តែង..................... ១៧ ៨៨៨ ៣១២,៦ លានរៀល
  + ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) អនុវត្តជាក់ស្តែង.......................................... ១០ ៥១០ ១៨៨,៥ លានរៀល
- អតិរេកនៃថវិកាចរន្ត .................................. (+)៦ ៩៧២ ៥៥៣,២ លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ.......................... (-)៣ ៤៩៣ ៧០៣,៦ លានរៀល
- ហិរញ្ញប្បទាននៃឱនភាព .................................. (+)៣ ៤៩៣ ៧០៣,៦ លានរៀល
  + ហិរញ្ញប្បទានក្រៅប្រទេស.......................... (+) ៥ ៩៧០ ៤៩៧,៣ លានរៀល
  + ហិរញ្ញប្បទានក្នុងប្រទេស.......................... (-) ២ ៤៤៨ ៨៩៣,៧ លានរៀល
    - បញ្ញើរាជរដ្ឋាភិបាល.............................. (-) ២ ៤៤៨ ៨៩៣,៧ លានរៀល
  + ហិរញ្ញប្បទានពីទីផ្សារហិរញ្ញវត្ថុ........................ (+) ៧២ ១០០,០ លានរៀល
    - បោះផ្សាយមូលបត្ររដ្ឋ.............................. (+) ៧២ ១០០,០ លានរៀល។

តុល្យភាពនៃថវិកាថ្នាក់ជាតិ ដែលបានសម្រេចជាស្ថាពរ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **ក២** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

# ជំពូកទី២
# កិច្ចប្រតិបត្តិការថវិកាថ្នាក់ក្រោមជាតិ
## ផ្នែកទី១
## កិច្ចប្រតិបត្តិការទូទៅ

**មាត្រា១១ .-**

ត្រូវបានយល់ព្រមលើការអនុវត្តជំពូកទី៤ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២២១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

លទ្ធផលដែលបានសម្រេចពីការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ : កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **ក៣** កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **ក៤** និងកិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្ហាញលម្អិតនៅក្នុងតារាង **ក៥** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

## ផ្នែកទី២
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

**មាត្រា១២ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................ ២ ៨៦៧ ៤២១,៦ លានរៀល
- អនុវត្តជាក់ស្តែង........................................ ៣ ៣០៨ ៧២០,១ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត អនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុ........................................ ៤៤១ ២៩៨,៦ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ១ ៨៣១ ៨៧០,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២ ៣១១ ០៩៩,៧ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ........................................ ៤៧៩ ២២៩,៧ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ........................................ ៧៦៦ ៨៩២,៦ លានរៀល
- អនុវត្តជាក់ស្តែង........................................ ៧៣៤ ៦៦៣,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................ ៣២ ២២៩,១ លានរៀល។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

ក. ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត

- ច្បាប់ហិរញ្ញវត្ថុ........................................................១៤ ៧៣៤,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................១៤ ៧៣៤,០ លានរៀល។

ខ. ការប្រគល់មុខងារសុខាភិបាល

- ច្បាប់ហិរញ្ញវត្ថុ................................................... ៧៥២ ១៥៨,៦ លានរៀល
- អនុវត្តជាក់ស្តែង...................................................៧១៩ ៩២៩,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.........................................៣២ ២២៩,១ លានរៀល។

៣. ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

- ច្បាប់ហិរញ្ញវត្ថុ...................................................... ២៦៨ ៦៥៩,០ លានរៀល
- អនុវត្តជាក់ស្តែង......................................................២៦២ ៩៥៧,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................... ៥ ៧០២,០ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង **១២** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៣ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ....................................................២ ៨៦៧ ៤២០,៦ លានរៀល
- អនុវត្តជាក់ស្តែង..................................................៣ ១៨៩ ៩៣៦,៥ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្តអនុវត្តបានខ្ពស់ជាង

ច្បាប់ហិរញ្ញវត្ថុ.........................................................៣២២ ៥១៦,០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណាយចរន្ត

- ច្បាប់ហិរញ្ញវត្ថុ....................................................២ ៤៣៤ ២៤២,៦ លានរៀល
- អនុវត្តជាក់ស្តែង..................................................២ ៧៥៦ ៥៩៦,៣ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ.........................................៣២២ ៣៥៣,៧ លានរៀល។

២. ចំណាយមូលធន

- ច្បាប់ហិរញ្ញវត្ថុ........................................................៤៣៣ ១៧៨,០ លានរៀល
- អនុវត្តជាក់ស្តែង.......................................................៤៣៣ ៣៤០,២ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ.............................................................១៦២,២ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ១ នៃតារាង **ឥ៤** និងត្រូវបានលម្អិតតាមរដ្ឋបាលរាជធានី ខេត្ត និងតាមមុខសញ្ញានៅក្នុងតារាង **ឥ៥** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៤ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង.......................... ៣ ៣០៨ ៧២០,១ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.......................... ៣ ១៨៩ ៩៣៦,៥ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត..............(+)១១៨ ៧៨៣,៦ លានរៀល។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលមានទឹកប្រាក់ចំនួន(+)១១៨ ៧៨៣,៦ លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៣
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

**មាត្រា១៥ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ..................................................៥៩៧ ៧២៣,៥ លានរៀល
- អនុវត្តជាក់ស្តែង............................................... ៥៨៥ ៥៥៦,១ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ................................................. ១២ ១៦៧,៤ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលចរន្ត

- ច្បាប់ហិរញ្ញវត្ថុ........................................ ៣០ ៦៦១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................ ២៨ ៧០៣,០ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១ ៩៥៨,០ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ

- ច្បាប់ហិរញ្ញវត្ថុ........................................ ៥៤៨ ០៦៧,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................ ៥៤៦ ៤០៥,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ១ ៦៦២,០ លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក. ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក

- ច្បាប់ហិរញ្ញវត្ថុ........................................ ៤១០ ៥១១,០ លានរៀល
- អនុវត្តជាក់ស្តែង........................................៤១០ ២៥៣,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ....................................២៥៧,៨ លានរៀល។

ខ. ការប្រគល់មុខងារអប់រំ

- ច្បាប់ហិរញ្ញវត្ថុ........................................១៣៧ ៥៥៦,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................១៣៦ ១៥២,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ..................................១ ៤០៤,២ លានរៀល។

៣. ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ

- ច្បាប់ហិរញ្ញវត្ថុ...........................................១៨ ៩៩៥,០ លានរៀល
- អនុវត្តជាក់ស្តែង...........................................១០ ៤៤៧,៥ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ.................................. ៨ ៥៤៧,៥ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមមាតិកាថវិកានៅក្នុងតារាង **ខ៣** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៦ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ........................................៥៩៧ ៧២៣,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................៥៧៤ ១៥៩,២ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបានទាបជាង
ច្បាប់ហិរញ្ញវត្ថុ............................................ ២៣ ៥៦៤,៣ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ២ នៃតារាង **ឆ៤** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៧ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ចំណូលថវិកាអនុវត្តជាក់ស្តែង................................៥៨៥ ៥៥៦,១ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង.............................. ៥៧៤ ១៥៩,២ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក.................. (+)១១ ៣៩៦,៩ លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤២ថ្មី នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ អតិរេកថវិការបស់រដ្ឋបាលក្រុង ស្រុក ដែលមានទឹកប្រាក់ចំនួន(+)១១ ៣៩៦,៩លានរៀល ត្រូវបានផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅធនាគារជាតិដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។

## ផ្នែកទី៤
## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

**មាត្រា១៨ .-**

កិច្ចប្រតិបត្តិការចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅ៖

- ច្បាប់ហិរញ្ញវត្ថុ.................................... ១ ០៨៦ ១៥២,៥ លានរៀល
- អនុវត្តជាក់ស្តែង.................................... ១ ១៣៣ ៧៩៣,៥ លានរៀល

ដូច្នេះ ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានខ្ពស់ជាង
ច្បាប់ហិរញ្ញវត្ថុ.................................... ៤៧ ៦៤១,០ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅ៖

១. ចំណូលមិនមែនសារពើពន្ធ
- ច្បាប់ហិរញ្ញវត្ថុ.................................... ០,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៤៧ ៦៤១,០ លានរៀល
- ខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ.................................... ៤៧ ៦៤១,០ លានរៀល។

២. ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ
- ច្បាប់ហិរញ្ញវត្ថុ.................................... ៨៤៧ ៣៥៧,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៨៤៧ ៣៥៧,០ លានរៀល

ក. ចំណូលសង្កាត់ចំណុះរាជធានី
- ច្បាប់ហិរញ្ញវត្ថុ.................................... ៤៥ ៤៧៦,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៤៥ ៤៧៦,០ លានរៀល។

ខ. ចំណូលសង្កាត់ចំណុះក្រុង
- ច្បាប់ហិរញ្ញវត្ថុ.................................... ៧០ ៤៤៣,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៧០ ៤៤៣,០ លានរៀល។

ចំណូលឃុំ
- ច្បាប់ហិរញ្ញវត្ថុ.................................... ៧៣១ ៤៣៨,០ លានរៀល
- អនុវត្តជាក់ស្តែង.................................... ៧៣១ ៤៣៨,០ លានរៀល។

៣. អតិរេកឆ្នាំ២០២១.................................... ២៣៨ ៧៩៥,៥ លានរៀល។

ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមមាតិកានៅក្នុងតារាង **២៤** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា១៩ .-**

កិច្ចប្រតិបត្តិការចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ ដូចមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅៈ

- ច្បាប់ហិរញ្ញវត្ថុ........................................១ ០៨៦ ១៥២,៥ លានរៀល
- អនុវត្តជាក់ស្តែង........................................៨៨១ ៨៨៣,៤ លានរៀល

ដូច្នេះ ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្តបានទាបជាង

ច្បាប់ហិរញ្ញវត្ថុ........................................២០៤ ២៦៩,១ លានរៀល

ដែលជាលទ្ធផលនៃការអនុវត្តដូចតទៅៈ

១. ចំណាយសង្កាត់ចំណុះរាជធានី

- ច្បាប់ហិរញ្ញវត្ថុ........................................៦០ ៧៥៧,៤ លានរៀល
- អនុវត្តជាក់ស្តែង........................................៤៧ ៦៣៧,៩ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................១៣ ១១៩,៥ លានរៀល។

២. ចំណាយសង្កាត់ចំណុះក្រុង

- ច្បាប់ហិរញ្ញវត្ថុ........................................៩៤ ៧៨៥,៩ លានរៀល
- អនុវត្តជាក់ស្តែង........................................៧៣ ១១៤,៣ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................២១ ៦៧១,៦ លានរៀល។

៣. ចំណាយឃុំ

- ច្បាប់ហិរញ្ញវត្ថុ........................................៩៣០ ៦០៩,២ លានរៀល
- អនុវត្តជាក់ស្តែង........................................៧៦១ ១៣១,២ លានរៀល
- ទាបជាងច្បាប់ហិរញ្ញវត្ថុ........................................១៦៩ ៤៧៨,០ លានរៀល។

ចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានបង្ហាញលម្អិតតាមជំពូកនៅក្នុងចំណុច ៣ នៃតារាង **ឌ៤** ដូចមានភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា២០ .-**

ការអនុវត្តកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ សម្រេចបានលទ្ធផលដូចតទៅៈ

- ចំណូលថវិកាអនុវត្តជាក់ស្តែង........................................១ ១៣៣ ៧៩៣,៥ លានរៀល
- ចំណាយថវិកាអនុវត្តជាក់ស្តែង........................................៨៨១ ៨៨៣,៤ លានរៀល
- អតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់........................................(+)២៥១ ៩១០,១ លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ អតិរេកថវិការបស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២២ ដែលមានទឹកប្រាក់ចំនួន(+)២៥១ ៩១០,១លានរៀល ត្រូវយោងបន្តទៅឆ្នាំ២០២៣។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២២ .-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០២៣

ពរល.២៣១២.២៦៣២

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក១

## កិច្ចប្រតិបត្តិការទូទៅថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបចំណូល = ( I.១ + II.១ ) | 30.544.366,0 | 32.299.330,9 | 105,7% | +1.754.964,9 |
| សរុបចំណាយ = ( I.២ + II.២ ) | 33.079.266,0* | 29.850.447,2 | 90,2% | -3.228.818,8 |
| លទ្ធផលពីការអនុវត្តថវិកាក្នុងឆ្នាំ | | +2.448.883,7 | | |
| I. កិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិកាថ្នាក់ជាតិ ដែលបានអនុវត្តឆ្លងកាត់រតនាគារជាតិ | | | | |
| I.១.ចំណូលថវិកា | 24.730.882,0 | 26.694.796,5 | 107,9% | +1.963.914,5 |
| • ចំណូលចរន្ត | 22.157.343,0 | 24.860.865,8 | 112,2% | +2.703.522,8 |
| • ចំណូលមូលធន | 2.573.539,0 | 1.833.930,6 | 71,3% | -739.608,4 |
| + ចំណូលមូលធនក្នុងប្រទេស | 1.305.259,0 | 116.031,7 | 8,9% | -1.189.227,3 |
| + ចំណូលមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍ | 1.268.280,0 | 1.717.898,9 | 135,5% | +449.618,9 |
| I.២.ចំណាយថវិកា | 27.265.782,0 | 24.245.912,8 | 88,9% | -3.019.869,2 |
| • ចំណាយចរន្ត | 19.111.704,0* | 17.888.312,6 | 93,6% | -1.223.391,4 |
| • ចំណាយមូលធន | 8.154.078,0 | 6.357.600,2 | 78,0% | -1.796.477,8 |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6.676.421,0 | 4.905.654,1 | 73,5% | -1.770.766,9 |
| + ការទូទាត់ការខ្ចី | 1.477.657,0 | 1.451.946,1 | 98,3% | -25.710,9 |
| II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | | | |
| II.១.ចំណូលមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | 5.813.484,0 | 5.604.534,4 | 96,4% | -208.949,6 |
| II.២.ចំណាយមូលធនសម្រាប់គម្រោងដោយហិរញ្ញប្បទានក្រៅប្រទេស | 5.813.484,0 | 5.604.534,4 | 96,4% | -208.949,6 |

(*)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមចំនួន៥០២ ៤០០លានរៀល ដោយយោងការធ្វើនិយ័តភាវូបនីយកម្ម នៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣



# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក២

## តុល្យភាពនៃថវិកាថ្នាក់ជាតិ

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I- ចំណូលក្នុងប្រទេសសរុប | 24.904.797,5 | |
| I.១. ចំណូលចរន្ត | 24.860.865,8 | |
| I.២. ចំណូលមូលធនក្នុងប្រទេស (មិនគិតបញ្ចូលចំណូលបានមកពីការបោះផ្សាយមូលបត្ររដ្ឋ ចំនួន៧២ ១០០,០លានរៀល) | 43.931,7 | |
| II. ចំណាយថវិកាសរុប | 28.398.501,1 | |
| II.១. ចំណាយចរន្ត | 17.888.312,6 | |
| II.២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចីចំនួន១ ៤៥១ ៩៤៦,១លានរៀល) | 10.510.188,5 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 4.905.654,1 | |
| - ដោយថវិកាថ្នាក់ជាតិ | 4.626.577,4 | |
| • គម្រោងវិនិយោគផ្ទាល់ | 3.963.346,1 | |
| • បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស | 663.231,3 | |
| - ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | 279.076,7 | |
| + វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 5.604.534,4 | |
| **ក. អតិរេកនៃថវិកាចរន្ត (I.១-II.១)** | (+)6.972.553,2 | |
| **ខ. ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II)** | (-)3.493.703,6 | |
| **III- ហិរញ្ញប្បទាននៃឱនភាព** | | (+)3.493.703,6 |
| **១. ហិរញ្ញប្បទានពីក្រៅប្រទេស** | | **(+)5.870.487,3** |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | (+)1.717.898,9 |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | (+)5.604.534,4 |
| • ការទូទាត់ការខ្ចី | | (-)1.451.946,1 |
| **២. ហិរញ្ញប្បទានក្នុងប្រទេស** | | **(-)2.448.883,7** |
| • បញ្ញើរាជរដ្ឋាភិបាល | | (-)2.448.883,7 |
| **៣. ហិរញ្ញប្បទានពីទីផ្សារហិរញ្ញវត្ថុ** | | **(+)72.100,0** |
| • ការបោះផ្សាយមូលបត្ររដ្ឋ | | (+)72.100,0 |

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក៣

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលរាជធានី ខេត្ត | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| ុបចំណូលថវិកា | 2.867.421,6 | 3.308.720,1 | 115,4% | +441.298,6 |
| ុបចំណាយថវិកា | 2.867.420,6 | 3.189.936,5 | 111,2% | +322.516,0 |
| តិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +118.783,6 | | |
| ច្ចប្រតិបត្តិការថវិកាបេស់រដ្ឋបាលរាជធានី ខេត្ត | | | | |
| ចំណូលថវិកា | 2.867.421,6* | 3.308.720,1 | 115,4% | +441.298,6 |
| - ចំណូលចរន្ត | 1.831.870,0 | 2.311.099,7 | 126,2% | +479.229,7 |
| • ចំណូលសារពើពន្ធ | 1.584.127,0 | 2.008.591,4 | 126,8% | +424.464,4 |
| • ចំណូលមិនមែនសារពើពន្ធ | 247.743,0 | 302.508,3 | 122,1% | +54.765,3 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 766.892,6 | 734.663,5 | 95,8% | -32.229,1 |
| • ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត | 14.734,0 | 14.734,0 | 100,0% | 0,0 |
| • ការប្រគល់មុខងារសុខាភិបាល | 752.158,6 | 719.929,5 | 95,7% | -32.229,1 |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 268.659,0 | 262.957,0 | 97,9% | -5.702,0 |
| . ចំណាយថវិកា | 2.867.420,6** | 3.189.936,5 | 111,2% | +322.516,0 |
| - ចំណាយចរន្ត | 2.434.242,6 | 2.756.596,3 | 113,2% | +322.353,7 |
| - ចំណាយមូលធន | 433.178,0 | 433.340,2 | 100,1% | +162,2 |

*) តួលេខនេះបូកបញ្ចូលនូវការបន្ថែមឥណទានថវិកាផ្តល់ជូនរដ្ឋបាលរាជធានី ខេត្ត ចំនួន៧ ៧៦៩,៥៦លានរៀល ក្នុងនោះ ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត ចំនួន១ ៤៣០លានរៀល សម្រាប់ផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ) និងការប្រគល់មុខងារសុខាភិបាល ចំនួន៦ ៣៣៩,៥៦លានរៀល ផ្តល់ជូនមន្ទីរសុខាភិបាលរាជធានី ខេត្ត ចំនួន១០។

**) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកានិយ័តកម្មថ្នាក់ជាតិផ្តល់ជូនសាលាខេត្តសៀមរាប (មូលនិធិអភិរក្សនិងអភិវឌ្ឍន៍តំបន់អង្គរ) ចំនួន១ ៤៣០លានរៀល និងប្រកាសបន្ថែមឥណទានថវិកា ចំនួន៦ ៣៣៩,៥៦លានរៀល ផ្តល់ជូនមន្ទីរសុខាភិបាលរាជធានី ខេត្ត ចំនួន១០ សម្រាប់ចំណាយបន្ទុកបុគ្គលិក។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក៤

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលក្រុង ស្រុក | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ(-) |
| ុបចំណូល | 597.723,5 | 585.556,0 | 98,0% | -12.167,5 |
| ុបចំណាយ | 597.723,5 | 574.159,2 | 96,1% | -23.564,3 |
| តិរកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +11.396,8 | | |
| ច្ចប្រតិបត្តិការនៃថវិកាបស់រដ្ឋបាលក្រុង ស្រុក | | | | |
| ចំណូលថវិកា | 597.723,5 | 585.556,0 | 98,0% | -12.167,5 |
| - ចំណូលចរន្ត | 30.661,0 | 28.703,0 | 93,6% | -1.958,0 |
| •ចំណូលមិនមែនសារពើពន្ធ | 30.661,0* | 28.703,0 | 93,6% | -1.958,0 |
| - ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | 548.067,5 | 546.405,5 | 99,7% | -1.662,0 |
| •ឧបត្ថម្ភធនដល់រដ្ឋបាលរដ្ឋបាលក្រុង ស្រុក | 410.511,0** | 410.253,2 | 99,9% | -257,8 |
| •ការប្រគល់មុខងារអប់រំ | 137.556,5*** | 136.152,3 | 99,0% | -1.404,2 |
| - ចំណូលឧបត្ថម្ភពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | 18.995,0 | 10.447,5 | 55,0% | -8.547,5 |
| ចំណាយថវិកា | 597.723,5 | 574.159,2 | 96,1% | -23.564,3 |
| - ចំណាយចរន្ត | 597.623,5**** | 574.061,2 | 96,1% | -23.562,3 |
| - ចំណាយមូលធន | 100,0***** | 98,0 | 98,0% | -2,0 |

*) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាបន្ថែមដល់រដ្ឋបាលក្រុង ស្រុក ចំនួន១៨ ៤២១,០លានរៀល ក្នុងនោះ : (១)-ឥណទានថវិកា នួន១៧៨,០លានរៀល ប្រភពពីចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ សម្រាប់បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ២)-ឥណទានថវិកាចំនួន៨ ០០០,០លានរៀល សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថានក្រុងគោលដៅទាំង២៨ (៣)-ឥណទានថវិកា នួន៩ ៨៣៣,០លានរៀល ចំណូលសារពើពន្ធចែលរំលែកពីរដ្ឋបាលខេត្ត៤%ជូនរដ្ឋបាលក្រុង ស្រុក (៤)-ឥណទានថវិកាចំនួន៤១០,០ ានរៀល ថវិកាពីការផ្ទេរមុខងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ចំណាយអភិវឌ្ឍន៍

**) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន៨ ១២២,០លានរៀល ថវិកាពីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយអភិវឌ្ឍន៍

***) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន ៣ ១២៧,៥លានរៀល ថវិកាសម្រាប់អនុវត្តមុខងារអប់រំនៅខេត្តបាត់ដំបង។

****)តួលេខនេះបូកបញ្ចូលនូវឥណទានថវិកានិយ័តកម្មថ្នាក់ជាតិចំនួន២៩ ៤៩២,៥លានរៀល ក្នុងនោះ : (១)-ចំណូលសារពើពន្ធចែករំលែក រដ្ឋបាលខេត្ត៤% ជូនរដ្ឋបាលក្រុង ស្រុកចំនួន៩ ៨៣៣,០លានរៀល (២)-ថវិកាសេវាអនាម័យបរិស្ថានចំនួន៨ ០០០,០លានរៀល (៣)-ថវិកា មូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន៨ ១២២,០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍(៤)-ថវិកាពីការផ្ទេរមុខងាររបស់ក្រសួង ភិវឌ្ឍន៍ជនបទ ចំនួន៤១០លានរៀល សម្រាប់ចំណាយអភិវឌ្ឍន៍ (៥)- ថវិកាសម្រាប់ការផ្ទេរមុខងារអប់រំនៅខេត្តបាត់ដំបងចំនួន៣ ១២៧,៥ ានរៀល និង(៦)-ឥណទានថវិកាចំនួន១៧៨,០លានរៀល ប្រភពពីចំណូលពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ សម្រាប់ បែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

*****) តួលេខនេះបូកបញ្ចូលនូវឥណទានថវិកាចំនួន៣៧ ១០០,០លានរៀល ប្រភពពីការផ្ទេរឥណទានថវិកាពីចំណាយចរន្តជំពូក៦៩ ចំណាយមិនបានវិភាជទុក

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក៥

## កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការថវិកា របស់រដ្ឋបាលឃុំ សង្កាត់ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | % ច្បាប់ | លើស(+)/ខ្វះ (-) |
| សរុបចំណូល | 1.086.152,5 | 1.133.793,5 | 104,4% | +47.641,0 |
| សរុបចំណាយ | 1.086.152,5 | 881.883,4 | 81,2% | -204.269,1 |
| អតិរេកពីការអនុវត្តថវិកាក្នុងឆ្នាំ | | +251.910,1 | | |
| កិច្ចប្រតិបត្តិការនៃថវិការបស់រដ្ឋបាលឃុំ សង្កាត់ | | | | |
| I. ចំណូលថវិកា | 1.086.152,5 | 1.133.793,5 | 104,4% | +47.641,0 |
| - ចំណូលមិនមែនសារពើពន្ធ | 0,0 | 47.641,0 | | +47.641,0 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 0,0 | 317,0 | | +317,0 |
| · ចំណូលសង្កាត់ចំណុះក្រុង | 0,0 | 5.125,5 | | +5.125,5 |
| · ចំណូលឃុំ | 0,0 | 42.198,4 | | +42.198,4 |
| - ចំណូលឧបត្ថម្ភពីថវិកាជាតិសរុប | 847.357,0 | 847.357,0 | 100,0% | 0,0 |
| · ចំណូលសង្កាត់ចំណុះរាជធានី | 45.476,0 | 45.476,0 | 100,0% | 0,0 |
| · ចំណូលសង្កាត់ចំណុះក្រុង | 70.443,0 | 70.443,0 | 100,0% | 0,0 |
| · ចំណូលឃុំ | 731.438,0 | 731.438,0 | 100,0% | 0,0 |
| - អតិរេកឆ្នាំ២០២១ | 238.795,5* | 238.795,5 | 100,0% | 0,0 |
| II. ចំណាយថវិកា | 1.086.152,5 | 881.883,4 | 81,2% | -204.269,1 |
| - ចំណាយសរុប | 1.086.152,5 | 881.883,4 | 81,2% | -204.269,1 |
| · ចំណាយសង្កាត់ចំណុះរាជធានី | 60.757,4 | 47.637,9 | 78,4% | -13.119,5 |
| · ចំណាយសង្កាត់ចំណុះក្រុង | 94.785,9 | 73.114,3 | 77,1% | -21.671,6 |
| · ចំណាយឃុំ | 930.609,2 | 761.131,2 | 81,8% | -169.478,0 |

(*) តួលេខនេះបូកបញ្ចូលនូវឥណទានចំនួន២៣៨ ៧៩៥,៤លានរៀល ដោយយោងការធ្វើនិយ័តការូបនីយកម្មនៃកិច្ចប្រតិបត្តិការ ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឯកតា: រៀល

# ការគ្រប់គ្រងឆ្នាំ២០២២
## តារាង ២១
## ចំណូលថវិកាថ្នាក់ជាតិ

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| សរុបរួមចំណូលថវិកា (I+II) | | | | 30.544.366.000.000 | 32.299.330.912.627 | 105,7% | +1.754.964.912.627 |
| I. សរុបចំណូលអនុវត្តឆ្លងកាត់ធនាគារជាតិ (ក+ខ) | | | | 24.730.882.000.000 | 26.694.796.479.027 | 107,9% | +1.963.914.479.027 |
| ក្នុងនោះ ចំណូលក្នុងប្រទេស | | | | 23.462.602.000.000 | 24.976.897.579.237 | 106,5% | +1.514.295.579.237 |
| ក. សរុបចំណូលចរន្ត (ក្រុមទី១) | | | | 22.157.343.000.000 | 24.860.865.843.368 | 112,2% | +2.703.522.843.368 |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 22.157.343.000.000 | 24.860.865.843.368 | 112,2% | +2.703.522.843.368 |
| | ប្រភេទទី១: ចំណូលសារពើពន្ធ | | | 20.227.005.000.000 | 22.585.224.596.017 | 111,7% | +2.358.219.596.017 |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 17.815.300.000.000 | 19.998.916.552.154 | 112,3% | +2.183.616.552.154 |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 5.481.000.000.000 | 7.344.425.024.043 | 134,0% | +1.863.425.024.043 |
| | | 70011 | ពន្ធលើប្រាក់ចំណូល(រូបវន្តបុគ្គល) | 86.000.000.000 | 44.042.826.644 | 51,2% | -41.957.173.356 |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 4.400.000.000.000 | 6.080.459.704.933 | 138,2% | +1.680.459.704.933 |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 995.000.000.000 | 1.219.922.492.466 | 122,6% | +224.922.492.466 |
| | 7002 | | ពន្ធប្រយោល | 7.049.000.000.000 | 7.303.426.078.144 | 103,6% | +254.426.078.144 |
| | | 70021 | អាករលើផលរបរ | 0 | 2.349.258 | | +2.349.258 |
| | | 70022 | អាករលើតម្លៃបន្ថែម | 3.111.000.000.000 | 3.123.672.636.051 | 100,4% | +12.672.636.051 |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ទនៈ) | 800.500.000.000 | 904.680.569.803 | 113,0% | +104.180.569.803 |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.137.500.000.000 | 3.275.070.523.032 | 104,4% | +137.570.523.032 |
| | 7003 | | អាករពិសេស | 5.125.300.000.000 | 5.191.038.846.698 | 101,3% | +65.738.846.698 |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 1.000.000.000.000 | 916.473.700.660 | 91,6% | -83.526.299.340 |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ទនៈ) | 653.500.000.000 | 660.270.212.837 | 101,0% | +6.770.212.837 |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 3.396.800.000.000 | 3.538.641.054.421 | 104,2% | +141.841.054.421 |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 75.000.000.000 | 75.653.878.780 | 100,9% | +653.878.780 |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 160.000.000.000 | 160.026.603.269 | 100,1% | +26.603.269 |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 160.000.000.000 | 160.026.603.269 | 100,1% | +26.603.269 |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.411.705.000.000 | 2.586.308.043.863 | 107,2% | +174.603.043.863 |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.371.245.000.000 | 2.529.646.255.633 | 106,7% | +158.401.255.633 |
| | | 71001 | ពន្ធគយពីការនាំចូល | 1.687.600.000.000 | 1.715.215.856.790 | 101,6% | +27.615.856.790 |
| | | 71002 | កម្រៃពីការងារគយ | 30.500.000.000 | 24.647.962.682 | 80,8% | -5.852.037.318 |
| | | 71003 | ពន្ធគយលើផលិតផលគេលសិលា | 265.300.000.000 | 358.175.062.927 | 135,0% | +92.875.062.927 |
| | | 71004 | អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ | 370.000.000.000 | 394.467.023.290 | 106,6% | +24.467.023.290 |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | 200.000.000 | 293.508.616 | 146,8% | +93.508.616 |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 17.645.000.000 | 36.846.841.328 | 208,8% | +19.201.841.328 |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 40.460.000.000 | 56.661.788.230 | 140,0% | +16.201.788.230 |
| | | 71011 | អាករលើការនាំចេញឈើ | 10.400.000.000 | 5.956.849.991 | 57,3% | -4.443.150.009 |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 17.100.000.000 | 14.065.130.783 | 82,3% | -3.034.869.217 |
| | | [illegible] | អាករលើការនាំចេញទំនិញផ្សេងៗ | 12.800.000.000 | 36.296.689.772 | 283,6% | +23.496.689.772 |
| | | [illegible] | ពិន័យផ្សេងៗពីការនាំចេញ | 160.000.000 | 343.117.684 | 214,4% | +183.117.684 |

# ការគ្រប់គ្រងឆ្នាំ២០២២

# តារាង ២១

# ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | **1.930.338.000.000** | **2.275.641.247.351** | **117,9%** | **+345.303.247.351** |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 173.953.000.000 | 415.137.162.976 | 238,6% | +241.184.162.976 |
| | 7200 | | ផលសម្បទាន | 166.423.000.000 | 122.152.495.483 | 73,4% | -44.270.504.517 |
| | | 72002 | ផលពីព្រៃឈើ | 9.492.000.000 | 7.499.582.242 | 79,0% | -1.992.417.758 |
| | | 72003 | សម្បទានប្រេងកាត | 720.700.000 | 0 | 0.0% | -720.700.000 |
| | | 72004 | សម្បទានរ៉ែ | 136.204.300.000 | 99.444.677.458 | 73,0% | -36.759.622.542 |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 11.500.000.000 | 11.336.971.355 | 98,6% | -163.028.645 |
| | | 72008 | ផលសម្បទានផ្សេងៗ | 8.506.000.000 | 3.871.264.428 | 45,5% | -4.634.735.572 |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 7.530.000.000 | 292.984.667.493 | 3.890,9% | +285.454.667.493 |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 7.530.000.000 | 292.984.667.493 | 3.890,9% | +285.454.667.493 |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 1.424.996.300.000 | 1.494.840.235.247 | 104,9% | +69.843.935.247 |
| | 7300 | | ផលទុនតាមវិស័យ | 550.429.100.000 | 553.389.448.601 | 100,5% | +2.960.348.601 |
| | | 73001 | ផលទុនអាកាសចរណ៍ស៊ីវិល | 55.550.000.000 | 51.115.130.761 | 92,0% | -4.434.869.239 |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 98.950.000.000 | 43.513.581.685 | 44,0% | -55.436.418.315 |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 4.412.200.000 | 3.894.464.977 | 88,3% | -517.735.023 |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 384.828.000.000 | 448.386.866.346 | 116,5% | +63.558.866.346 |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 806.400.000 | 495.524.000 | 61,4% | -310.876.000 |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 0 | 91.095.700 | | +91.095.700 |
| | | 73008 | ផលទុនផ្សេងៗទៀត | 5.882.500.000 | 5.892.785.132 | 100,2% | +10.285.132 |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 94.819.000.000 | 136.278.713.399 | 143,7% | +41.459.713.399 |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 120.000.000 | 47.470.000 | 39,6% | -72.530.000 |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 94.515.000.000 | 135.937.591.599 | 143,8% | +41.422.591.599 |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 139.000.000 | 122.000.000 | 87,8% | -17.000.000 |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬខូច | 45.000.000 | 167.769.800 | 372,8% | +122.769.800 |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬខូច | 0 | 3.882.000 | | +3.882.000 |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (១) | 69.312.800.000 | 106.097.083.272 | 153,1% | +36.784.283.272 |
| | | 73022 | ផលពីការចុះបញ្ជីគណបក្សនយោបាយ | 6.000.000 | 0 | 0.0% | -6.000.000 |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 28.556.700.000 | 39.885.146.283 | 139,7% | +11.328.446.283 |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 1.728.900.000 | 2.438.675.771 | 141,1% | +709.775.771 |
| | | 73026 | ចំណូលពីប្រដាប់ភ្លើ | 5.002.400.000 | 6.400.534.305 | 127,9% | +1.398.134.305 |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 34.018.800.000 | 57.372.726.913 | 168,7% | +23.353.926.913 |
| | 7304 | | [illegible]សកម្ម | 37.902.100.000 | 45.550.663.769 | 120,2% | +7.648.563.769 |
| | | [illegible] | [illegible]ប៊ែទាំ | 8.650.700.000 | 17.360.876.975 | 200,7% | +8.710.176.975 |
| | | [illegible] | [illegible] | 13.500.000.000 | 8.371.183.751 | 62,0% | -5.128.816.249 |
| | | [illegible] | [illegible]បត្រថ្កោលទោស | 2.702.400.000 | 3.622.450.000 | 134,0% | +920.050.000 |
| | | [illegible] | [illegible]ប្រដាប់ត្រា | 3.500.000.000 | 4.816.811.400 | 137,6% | +1.316.811.400 |



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២២

# តារាង ២១

# ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 9.549.000.000 | 11.379.341.643 | 119,2% | +1.830.341.643 |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 201.076.500.000 | 191.591.101.300 | 95,3% | -9.485.398.700 |
| | | 73061 | ចំណូលពីភតិកិច្ចកាស៊ីណូ | 148.566.800.000 | 79.611.171.288 | 53,6% | -68.955.628.712 |
| | | 73062 | ចំណូលពីភតិកិច្ចឆ្នោត | 2.352.800.000 | 3.613.455.938 | 153,6% | +1.260.655.938 |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 35.000.000 | 40.900.000 | 116,9% | +5.900.000 |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 23.196.900.000 | 77.060.743.716 | 332,2% | +53.863.843.716 |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 26.925.000.000 | 31.264.830.358 | 116,1% | +4.339.830.358 |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 32.085.300.000 | 34.510.015.602 | 107,6% | +2.424.715.602 |
| | | 73071 | ការជួលដីទំនេរ | 16.863.400.000 | 19.451.319.608 | 115,3% | +2.587.919.608 |
| | | 73072 | ការជួលដីមានអគារ | 13.849.900.000 | 13.110.008.994 | 94,7% | -739.891.006 |
| | | 73073 | ការជួលអគារ ឬសំណង់ផ្សេងៗ | 1.096.400.000 | 1.729.979.960 | 157,8% | +633.579.960 |
| | | 73074 | ការជួលសម្ភារ បរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 275.600.000 | 201.192.200 | 73,0% | -74.407.800 |
| | | 73078 | ផលពីការជួលផ្សេងៗ | 0 | 17.514.840 | | +17.514.840 |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (២) | 439.371.500.000 | 427.423.209.304 | 97,3% | -11.948.290.696 |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 106.526.400.000 | 95.135.869.887 | 89,3% | -11.390.530.113 |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 274.083.200.000 | 233.416.355.842 | 85,2% | -40.666.844.158 |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 8.500.000.000 | 19.783.590.033 | 232,7% | +11.283.590.033 |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 4.640.000.000 | 16.732.086.071 | 360,6% | +12.092.086.071 |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 1.182.000.000 | 3.328.911.502 | 281,6% | +2.146.911.502 |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 5.026.000.000 | 4.904.377.400 | 97,6% | -121.622.600 |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 39.413.900.000 | 54.122.018.569 | 137,3% | +14.708.118.569 |
| 74 | | | **ចំណូលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម** | **65.765.300.000** | **100.852.329.215** | **153,4%** | **+35.087.029.215** |
| | 7401 | | ផលពីការដាក់ពិន័យ និងការដាក់ទណ្ឌកម្ម | 52.297.300.000 | 98.459.022.662 | 188,3% | +46.161.722.662 |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 34.000.000.000 | 18.273.827.600 | 53,7% | -15.726.172.400 |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 18.297.300.000 | 80.185.195.062 | 438,2% | +61.887.895.062 |
| | 7403 | | ចំណូលពីការរឹបអូស | 12.000.000.000 | 377.362.628 | 3,1% | -11.622.637.372 |
| | | 74031 | ចំណូលពីការរឹបអូសប្រាក់កក់ | 0 | 28.490.000 | | +28.490.000 |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 12.000.000.000 | 348.872.628 | 2,9% | -11.651.127.372 |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 1.468.000.000 | 2.015.943.925 | 137,3% | +547.943.925 |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 1.468.000.000 | 2.015.943.925 | 137,3% | +547.943.925 |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | **92.255.000.000** | **93.517.692.514** | **101,4%** | **+1.262.692.514** |
| | 7504 | | ឧបត្ថម្ភធនពីក្រៅប្រទេស | 90.000.000.000 | 90.438.498.084 | 100,5% | +438.498.084 |
| | | 75041 | ឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគី | 90.000.000.000 | 90.438.498.084 | 100,5% | +438.498.084 |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 2.255.000.000 | 3.079.194.430 | 136,5% | +824.194.430 |
| | | 75081 | ផល[illegible]ចំណែកការពារបរិស្ថាន | 2.255.000.000 | 3.079.194.430 | 136,5% | +824.194.430 |
| 76 | | | **ផលហិរញ្ញវត្ថុ** | **173.328.000.000** | **153.616.375.615** | **88,6%** | **-19.711.624.385** |
| | 760[illegible] | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | 173.328.000.000 | 136.724.932.826 | 78,9% | -36.603.067.174 |

# ការគ្រប់គ្រងឆ្នាំ២០២២

# តារាង ២១

# ចំណូលថវិកាថ្នាក់ជាតិ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ឆ្នាំ២០២២ | | អនុវត្ត/ច្បាប់ហិរញ្ញវត្ថុ | |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | %ច្បាប់ | លើស(+)/ខ្វះ(-) |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 173.328.000.000 | 136.724.932.826 | 78,9% | -36.603.067.174 |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងទៀត | 0 | 16.891.442.789 | | +16.891.442.789 |
| | | 76981 | ផលហិរញ្ញវត្ថុផ្សេងទៀត | 0 | 16.891.442.789 | | +16.891.442.789 |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | 40.400.000 | 17.677.451.784 | 43.756,1% | +17.637.051.784 |
| | 7701 | | ចំណូលពីការបង់អតិរេក និងកម្រៃនៃកិច្ចប្រតិបត្តិការគ្រប់គ្រងផ្សេងៗ | 0 | 24.009.858 | | +24.009.858 |
| | | 77013 | កម្រៃធនាគារ | 0 | 24.009.858 | | +24.009.858 |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 34.400.000 | 11.381.335.868 | 33.085,3% | +11.346.935.868 |
| | | 77021 | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (លក់) | 0 | 10.308.626.271 | | +10.308.626.271 |
| | | 77022 | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ (ដោះដូរ) | 34.400.000 | 1.072.709.597 | 3.118,3% | +1.038.309.597 |
| | 7704 | | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 0 | 7.400.000 | | +7.400.000 |
| | | 77041 | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 0 | 7.400.000 | | +7.400.000 |
| | 7705 | | ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខាជាអចលនវត្ថុ | 6.000.000 | 0 | 0.0% | -6.000.000 |
| | | 77052 | ចំណូលពីការលក់រថយន្ត | 3.000.000 | 0 | 0.0% | -3.000.000 |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | 3.000.000 | 0 | 0.0% | -3.000.000 |
| | 7798 | | ផលពិសេសផ្សេងៗទៀត | 0 | 6.264.706.058 | | +6.264.706.058 |
| | | 77981 | ផលពិសេសផ្សេងៗទៀត | 0 | 6.264.706.058 | | +6.264.706.058 |
| **ខ.សរុបចំណូលមូលធន(ក្រុមទី១)** | | | | 2.573.539.000.000 | 1.833.930.635.659 | 71,3% | -739.608.364.341 |
